# ទារឯក[1]

## នេះសាស្ត្រាទារឯក

១- នេះនឹងដំណាលកាលដើមដាន
ស្តេចទ្រង់ព្រះនាមព្រះរាមា
មុនមានក្សត្រក្សាន្តសោយរាជា
គ្រប់គ្រងកម្ពុជាធិបតី ។

២- មានទាំងទេពីស្នំស្នេហា
ស្តេចទ្រង់ទសពិធដោយវិន័យ
មាត្យ[221]មុខសេនាព្រាហ្មណ៍ព្រឹទ្ធិ
រាស្ត្រទាសរកស៊ីសុខសាទរ ។

៣- នឹងលើកពីរឿងនាងទារឯក
ព្រោះតែនាងទារកើតហេតុរវ
អស្ចារ្យចម្លែកក្នុងនគរ
ឱ្យបញ្ចូល (ទៅ)[222]ជាអ្នកងារ ។

៤- នៅខែត្រត្បូងឃុំធំកណ្តាល
ហៅភូមិជើងខាលនឹងពណ៌នា
កាលដើមអាពុកឈ្មោះចៅរា
ម្តាយឯកណាឈ្មោះនាងប្រុក ។

៥- នៅរួមរកស៊ីជាមួយគ្នា
កបកើតទ្រព្យាគ្រាន់ដាក់ទុក
គ្រាន់ចាយសប្បាយសាន្តសុខ
រីឯនាងប្រុកផើមគ្រប់ខែ ។

៦- សម្រាលកូនមកក៏ប្រុសប្រាណ
អស់ញាតិសន្តានសោតសឹងតែ
ស្រឡាញ់ថ្នាក់ថ្នមពបំពេ
បានគ្រប់ថ្ងៃខែឈ្មោះឯកហោង ។

៧- កាលក្មេងតូចៗ នោះមាតា
បីបមរក្សាមិនឱ្យមានហ្មង
លុះធំសក្តិសមរូបឆោមផង
ឆ្នាំប្រាំពីរហោងទើបមាតា ។

៨- យកទៅនៅវត្តឱ្យគ្រូប្រៀន
កិច្ចការរបៀនសព្វអាហារ
លុះនៅតិចទៅទសមាសា
បួសនេននឹងមហាសង្ក្រាជថ្លៃ ។

៩- បួសជាសាមណេរនេនឧស្សាហ៍
រៀនសូត្រសាស្ត្រាធម៌បាលី
បំរើលោកគ្រូត្រូវព្រះទ័យ
មិនមានសង្ស័យក្នុងចិន្តា ។

១០- សូមអស់គាថាមន្តរបៀន
ដ្បិតចិត្តចង់រៀនឯទេសនា
គ្រូលោកក៏ណែទាំងវិជ្ជា
គ្មានសល់ត្រង់ណាតាមប៉ុនចិត្ត ។

---

[221] អមាត្យ (សំ.; បា. អមច្ច): មន្ត្រីជំនិតនឹងព្រះរាជា; សម្លាញ់ ។ ករិបង្រួមមួយព្យាង្គដើម្បីគោរពជើងកាព្យ ។

[222] J'ai ajouté ce mot pour compléter le nombre de syllabe de ce vers.



---

[1] តាមឯកសារសិក្សាស្រាវជ្រាវរបស់លោកបណ្ឌិតឃីង ហុកឌី (បោះពុម្ពឆ្នាំ២០០៥)

១១-មានកាលមួយ ថ្ងៃអស់បាសក ព្រមគ្នាទាំងស្រុកសមគំនិត
ចង់ស្តាប់ទេសនាជាផលពិត ដែលយើងរិះគិតពីមុនមក ។
១២-នឹងទៅនិមន្តលោកទេសនា នៅផ្ទះអាត្មាគិតលៃលក
អស់គ្រឿងបូជាផងរៀបមក បានអ្វីផងយកមកគ្រប់គ្នា ។
១៣-រៀបស្រេចដើរត្រាច់ចេញទៅ ឆ្ពោះត្រង់សំដៅព្រះវិហារ
នឹងនិមន្តលោកមកទេសនា តាមចិត្តប្រាថ្នាដែលចង់ស្តាប់ ។
១៤-ដៃកាន់ទៀនធូបគ្រឿងបូជា ស្លាបារីផ្កាដាក់ជើងស្រាប់
ដល់ឡើងលើកុដិឱនស្រពាប[223] សិរសាទន្ទាបថ្វាយបង្គំ ។
១៥-ហើយទើបពិតពុទ្ធដីកាថា ខ្ញុំព្រះករុណាមកសូមសុំ
និមន្តលោកគ្រូដ្បិទជាធំ ទេសនាផ្ទះខ្ញុំបានមួយកណ្ឌ ។
១៦-តាមតែព្រះទ័យមេត្តាប្រោស ញាតិញោមសន្តោសឆាប់ឱ្យទាន
សូមឱ្យលោកទេសន៍តែមួយកណ្ឌ ប្រញាប់រួសរាន់ក្រែងយប់ជ្រៅ ។
១៧-រីឯលោកគ្រូបានស្តែងស្តាប់ ពាក្យពេចន៍សារសព្ទអររចៅរ៉ៅ
ឮគេនិមន្តខ្លួនឱ្យទៅ ទេសនាឥឡូវថាពិតអើយ ។
១៨-(ឧ)បាសកឮហើយក្រាបលា ចុះចាកយាត្រាទៅផ្ទះហើយ
លោកគ្រូពីគ្រោះបែរងើបងើយ ហៅនេនឯកឆ្លើយប្រាប់ទៅថា ។
១៩-ឥឡូវអញចង់ប្រើនេនឯង ឱ្យរៀបចាត់ចែងតែងកាយា
(ឧ)បាសកនិមន្តទេសនា អញចង់ប្រើបាទៅទេសន៍ជួស ។
២០-អ្នកនេនឮពាក្យគ្រូប្រើប្រាណ ពុំហ៊ានប្រកែកឡើងទៅហួស
រៀបខ្លួនរៀបប្រាណដោយអ្នកបួស ដើរហួសទៅហៅនេនពេជ្រផង ។
២១-ប្រាប់ថាពេជ្រអើយជូនបងទៅ ឥឡូវលោកគ្រូលោកប្រើបង
មានតែប្អូនឯងតែងទៅផង លីគម្ពីរតាមបងទៅទេសនា ។
២២-ប្អូនអើយអ្នកកុំគិតប្រកែក វេរាអស់ឯកពុំយាត្រា

---

[223] គួរសរសេរ «ស្រប៉ប»(?)ទើបបានជាប់ចុងជួននឹងឃ្លាមុនហើយដែល
មានន័យថា«ដែលមានរាងទាបរាបស្រពាប» ។

អាសូរតែបងបានជាគ្នា
ក្រងាយម្ដេចម្ដាមានពីរនាក់ ។
២៣-នេនពេជ្រស្ដាប់ពាក្យនេនឯកហៅ
ត្រេកអរចៅរ៉ៅៗពាក្យជាក់
បងចង់ទៅណាប្អូនក៏ស្ម័គ្រ
ជូនអ្នកនេនទៅកុំឱ្យខាន ។
២៤-ស្បង់សោតសុទ្ធតែព្រៃចិនចៅ
អង្សក្រ័ប៉ាក់ចៅសមនឹងប្រាណ
រត្តពន្ធព្រៃផ្កានីណងក្រាន
មែនមានរស្មីនេនទាំងពីរ ។
២៥-សមន្ទូរសម្បុរភ្លឺច្រេះច្រោលត្រកាល
អ្នកនេនទាំងពីរស្រស់ពីសី
នេនឯកល្អប្លែករកគ្មានពីរ
ដោយតេជរិទ្ធីព្រះមន្ត្រខ្មី ។
២៦-លោកគ្រូយល់ហើយចូលក្នុងកុដិ
លំអុតពេនពង់ទ្រង់ពីធី
សារិកាសេកសោមនមោមេ
សន្តំសត្តេកែរករិក ។
២៧-ទាំងមហារងំបំបាំងកាយ
បាត់មុឺនរលាយនិងក្អែកទឹក
តែតាំងទេសនារៀលរអឹក
គ្មានភ្លឹកគ្មានភ្លេចព្រះបាលី ។
២៨-ហើយសែកឥតិបិសោមេថៃលាំង
សំកោកសំកាំងបាំងឥន្ទ្រីយ៍[224]
ការក្រែងអ្នកផងគេពាធី
បញ្ចូលករណីមកមិនដល់ ។
២៩-សែកទាំងគាថាព្រះសីដុក
សារិកាដាក់មុខកុំឱ្យឆ្ងល់
ការក្រែងអាបធ្មប់រាមកពាល់
រង់ដានទៅជារបង ។
៣០-សែកប្រេងម្សៅលាបជើងដៃ
ការអស់ចង្រៃកាចកន្លង
កុំឱ្យមានមកចូលលេងលង
ឱ្យដិងល្បិចល្បងអ្នកនេនឯក ។
៣១-លេខយន្តបញ្ចុះជើងធ្មេញគ្រប់
យន្តក្រួចផ្តល់ផ្ទប់រាជសីហ៍ស្រែក
រស្សរ័ណដាក់មុខអ្នកនេនឯក
គេមើលគ្រប់ភ្នែកខ្លាចស្ញប់ស្ញែង ។
៣២-កន្សែងបញ្ចុះសុទ្ធតែយន្ត
គាថាមួយពាន់ភ្លឺចិញ្ចែង
ទោះខ្មោចបីសាចក៏ខ្លាចក្រែង
អ្នកនេនឯកឯងពុំមានព្រឺ ។
៣៣-ទាំងមហារលួយមហារលាយ
ប្រទាលនាងស្វាយព្រាយតាមអរ
ប្អូននាក់តែនឹងដាក់បញ្ចើ
គ្រាន់ផ្ដុំបង្ហើរដើរដោយខ្យល់ ។
៣៤-សែកស្រេចអស់កិច្ចការគាថា
គ្មានខ្ទោះត្រង់ណាឱ្យអស់កល
តាមក្បួនខ្លួនរៀនអស់គ្មានសល់
រួចស្រេចអ្នកនេនលាចេញទៅ ។

224Cf. manuscrit sur papier (ms.) P.camb. 32, EFEO.

៣៥-នេនពេជ្រដើរមុនលីគម្ពីរ មាសគាធកម្ទីភ្លឺច្រាលឆ្អៅ
ដំណើរនេនឯកដើរក្រោយទៅ ឥតមានហ្មងសៅទៅទាំងសង ។

៣៦-លោកគ្រូសែកមន្តផ្លុំពីក្រោយ គាថាទៅដោយដិតទៅផង
តាមថ្នល់ផ្លូវឆ្ងាយក្រែកន្លង ឬអស់អ្នកផងមើលគ្រប់គ្នា ។

៣៧-ស្រីៗកេះគ្នាឱ្យមើលទៅ ឃើញនេនឆោមឆ្លៅពីរអង្គា
ចង្អុលបង្ហាញប្រាប់គ្នីគ្នា ថាន៍មើលវ៉ាល្អចម្លែក ។

៣៨-ប្រសិនជាបានមកអញវ៉ា នឹងថ្នមប្រវ៉ាទុកជាឯក
ឯនេនដើរក្រោយល្អចម្លែក នេះប្លែកទើបមកពីស្រុកណា ។

៣៩-អ្នកនេនដល់ហើយឡើងលើផ្ទះ បាសកសំពះឱនវន្ទា
ស្រេចហើយរៀបអស់គ្រឿងបូជា អារាធនានិមន្តលោកឡើងគង់ ។

៤០-នេនឯកសូត្រដាស់អាទិគាថា ហៅព្រាយកុមារមកជុំអង្គ
ហើយតាំងព្រះភ្នេនពេនពានពង់ លើកសាស្ត្រាផ្ទង់តាំងនមោ ។

៤១-ពុំមានញរ័មាត់ភ្លាត់ត្រង់ណា ធ្លាប់តែទេស្នាពីមុនមក
សម្លេងក្រឳនៅដើមក រនរអឹកខ្វរពីរោះក្រៃ ។

៤២-អធិប្បាយដោះស្រាយពីបាលី សេចក្តីកាលព្រះមកុដភពត្រៃ
សាងបារមីធួនបួនអសង្ខៃយ យកព្រះជាតិថ្លៃវេស្សន្តរ ។

៤៣-ទ្រង់បូទ្វសទ្ធាទិគុណខ្ជាប់ ស្នូមសូមព្រះរាជទ្រព្យគ្មានសល់ក្រ
ប្រទានទាំងនរេន្ទ្រគជេន្ទ្រអស្សតរ រាស្ត្រទាំងនគរខឹងរាល់គ្នា ។

៤៤-បណ្តេញព្រះអង្គទាំងទេពី ក្រីស្នាជាលីបួនអង្គា
ទៅគង់វង្កតសាងសទ្ធា ឥតមានរោគាក្សត្រឡើយណា ។

៤៥-ឯទារមៀងមើលយង់យល់ជាក់ ក្នុងចិត្រស្មោះស្ម័គ្រចង់ស្នេហា
គឺមោះមិនដឹងបើហ៊ានថា ដ្បិទខ្លួនសោតណាទាល់ជាស្រី ។

៤៦-នឹកតែក្នុងចិត្តប្រាថ្នាខ្ជាប់ ពុំហ៊ានបើប្រាប់អ្នកឯណានៃ
ខ្លួនក៏ទំនេរពុំមានប្តី ពុំហ៊ានស្រដីខ្មាស់អ្នកផង ។

៤៧-ក្នុងថ្លើមសាច់ស្ងួតដូចគេជ្រួយ ក្នុងទ្រូងរំជួយអស់អង្គា
ស្មារតីរង្វេងធ្វេសសូន្យសុង ស្មើរតែពុំគង់រស់រូបា ។

៤៨-គិតហើយយកគ្រឿងដាក់លើពាន ក្នុងចិត្តគិតអានជាប្រស្នា
ស្លាម្លូបារីម្ទូរចងជាប់គ្នា នាងលើកបូជាប្រគេនខ្មី ។
៤៩-នេនឯកទទួលបារីស្លា ដឹងជាប្រស្នាពុំស្រដី
លុះនេនទេស្នាចប់ហើយនៃ តែក្នុងព្រះទ័យ[225] ចង់ស្នេហា ។
៥០-បាសកលើកគ្រឿងបូជាមក ចេកអំពៅអង្ករដាក់បណ្ដាការ
ទៀនធូបគ្រប់អស់គ្នីគ្នា ថ្វាយស្រេចហើយនេនភត្តាឱ្យ ។
៥១-រីឯនាងទាវរ័ក្ខធីតា លើកបណ្ដាការទៅតាមដោយ
ចំណង់នៃចិត្រគិតថាឱ្យ បានបុណ្យព្រះដោយចិត្រប្រាថ្នា ។
៥២-លើកដាក់ចំពោះចំពីមុខ ដោយនាងគិតទុកក្នុងចិន្ដា
ទៅដល់នេនឯកប្លែកស្នេហា លូកដៃប្រវាទទួលខ្មី ។
៥៣-គន់ភ្លាំងស្លាំងកាំងទាំងកាយា ព្រោះឃើញចិន្ដាទាវមេត្រី
យល់រាងនាងល្អកល្យាណី ស្មើរស្លុតស្មារតីធ្ងេសរាយមាយ ។
៥៤-ថាឱរូបរាងស្រីនាងស្រីនេះ ល្អអីល្អម្ល៉េះស្មើស្នូគិនាយ
បើមើលឱ្យអស់ទាំងទ្រង់ទ្រាយ និងរកស្រីអាយនេះផ្ទឹមគ្មាន ។
៥៥-បើបានមកអញនេះតិចវ៉ា នឹងរក្សារូបារួមស្ថាន
មិនឱ្យប្អូនមិត្តមាសកល្យាណ អំពល់ព្រួយប្រាណដល់តិចឡើយ ។
៥៦-នេនឯកបបួលនេនពេជ្រថា ហៃប្អូនពុំងាមាសបងអើយ
រៀបម្ទូរគម្ពីរឱ្យស្រេចហើយ កែរអើយយើងទៅទាន់ពីថ្ងៃ ។
៥៧-អ្នកនេនគិតដូចក្នុងចិន្ដា ហើយលាបាសកទៅវត្តវៃ
ចូលថ្វាយបង្គំគ្រូហើយនៃ នេនឯកប្រាស្រ័យលាចង់សឹក្ខ ។
៥៨-ឯលោកគ្រូព្រមចំអន់ថា យ៉ាងមានសិកា[226] ផ្ញើរវរិក
ត្រូវមន្តវិជ្ជាការពីព្រឹក នេនពេជ្រក៏នឹកចង់សឹក្ខផង ។
៥៩-វិលមកដល់កុដិប្រះនិទ្រា គិតដល់សង្សារភក្ត្រសៅហ្មង

---

[225] ព្រះហទ័យ

[226] ឧបាសិកា

យកស្លាបារីស្រីទារចង
មកស្រោយចំណងដឹងប្រាជ្ញា ។

៦០-ស្លាចងបារីចងនាងឱ្យមក
ហើយផ្តាំឱ្យទៅកុំវេរា
ប៉ុនប៉ងនិងយកជាសង្សារ
ដាក់ពានស្លាថាទទួលហើយ ។

៦១-ឃើញហើយរំពឹងរឹងជាទុក្ខ
កើតតែអំពល់យល់ពុំស្រួល
តានតឹងចេរចុកអន់អាក់អួល
ថៃថប់រំជួលគ្រប់វេលា ។

៦២-ថប់ដ្បិតដល់គិតនោះគ្មានគេ
ថប់ប្តីក្រែងស្រីមិនមេត្តា
ថប់មួយខ្លាចខុសនឹងមេបា
ថប់ប្អូនដល់ការណាគ្មានប្រាក់ ។

៦៣-បើកផើយឡើងឃើញដួងតារា
ទឹកភ្នែកហូរល្វែងស្រក់ស្រាក់
ព្រះច័ន្ទជ្រះថ្លាភ្លឺត្រជាក់
គិតតែរលក្ខណ៍ពុំនិទ្រា ។

៦៤-លុះព្រឹកភ្លឺស្វាងបំព្រាងជាក់
ដល់ហើយឯកពេជ្រក្រាបវន្ទា
នេនទៅសំណាក់លោកអាចារ្យ
ចាកពីសិក្ខាទាំងពីរនាក់ ។

៦៥-ស្រេចលាលោកគ្រូទៅនៅផ្ទះ
រៀបទីឱ្យកូននៅសំណាក់
ឡើងទៅសំពះម្តាយរាក់ទាក់
ពុំមានឱ្យអាក់ចិត្តឯកឡើយ ។

៦៦-រៀបបាយរៀបទឹកទីដំណេក
ឯកចូលទៅដេករួចស្រេចហើយ
កន្ទេលឱ្យដេកពូកខ្នល់ខ្នើយ
តែចិត្តពុំស្បើយសោកដល់ស្រី ។

៦៧-លុះល្ងាចឯកក្រោកពីនិទ្រា
ហៅព្រាយកុមារមកឆាប់ក្រៃ
សែកដាស់គាថាទិសប្រាំបី
ហើយចរចេញវៃដល់ផ្ទះទារ ។

៦៨-ឯទារមៀងមើលឃើញអ្នកឯក
ស្គាល់ជាអ្នកប្រុសនោមស្រងៅ
ល្អល្អះចម្លែកឈរនៅក្រៅ
ស្រែកហៅមេនោមកមើលផង ។

៦៩-អង្គុយនិត្យនៅនាបង្អួច
ទន្ទឹងរឹងថប់ក្រៃកន្លង
ក្នុងចិត្តកើតគួចភក្រ្តសៅហ្មង
លុះឯកដល់ហោងបានស្បើយទុក្ខ ។

៧០-ទើបឯកឆ្លាស់ឆ្លើយឆ្លងវាចា
ឯបងនេះសោតសឹងកើតទុក្ខ
ថាហៃប្អូនភ្ញានាងបានសុខ
តាំងពីឈមមុខទុក្ខបងធ្ងន់ ។

៧១-ដ្បិតបងបានឃើញអាចិប្រស្នា
ឯក្នុងទ្រូងបងអាក់អួលអន់
ប្អូនមាសកាលណាហាក់ទុជិន
ស្មើរក្សរ័យជីពជន្មបងជាម្តង ។

៧២-ស្លាបារីស្រីចងជាប់ជាគូ
បងស្រាយមិនយូរឃើញហើយហោង

ថាប្អូនមិត្រមាសថ្លៃទងរង ប្អូនមេត្តាបងចង់មេត្រី ។
៧៣-ជាគូរួមរ័ក្សស្មគ្រមនោរម្យ ជាប្ដីឧត្តមសមជាតី
ចងចាំចិត្រជាប់ជាមេត្រី ហេតុនោះឯងនៃទើបបងមក ។
៧៤-ចូរប្អូនមិត្រមាសកែវទទួល ព្រើសព្រួចស្រាកស្រួលកុំនៃនក
ត្រូវទាំងជតាវាសីមក នាងចុះមកយកបងជាប្ដី ។
៧៥-នាងទាវស្ដែងស្ដាប់ពាក្យឯកជាក់ ឃើញជាស្មោះស្មគ្រទាក់សំដី
ព្រឺព្រួចកើតក្ដួចចាប់បេតី ជាតិជាដើម្បីប្ដីកំសត់ ។
៧៦-ឆ្លាស់ឆ្លើយពីពារតតបទៅ ថាអ្នកនិត្យនៅទីជនបទ
ស្រុកទេសដំបន់តើសន្មត ត្រង់ស្ថានកំណត់នៅត្រង់ណា ។
៧៧-ទាំងនាមខ្លួនអ្នកតើឈ្មោះអ្វី ចូរអ្នកស្រដីប្រាប់មកវ៉ា
បានជាអ្នកមករកប្អូនភ្ងា អ្នកមានវាចាថាប្អូនផ្កាំ ។
៧៨-ឯឯកឆ្លាយឆ្លើយតតបទៅ ថាហៃប្អូនពៅស្រស់ស្រងាំ
ប្រស្នាម្លូស្លាបារីផ្ដាំ ពាក្យពេចន៍សាំទាំឱ្យបងមក ។
៧៩-ថាប្អូនខ្លឹមខ្លួននាងទទួល រៀបរងស្រាកស្រួលចូលចិត្រយក
ជាគូមូលមិត្ររួមរ័ក្សរក ហេតុនេះបងមករកប្អូនស្រី ។
៨០-ឯខ្លួនបងនេះកាលដើមឡើយ ប្អូនអើយនៅស្រុកហៅភូមិថ្មី
ពីក្មេងពុំទាន់ដឹងសេចក្ដី បីតាមាតាលោកឱ្យឈ្មោះ ។
៨១-ចៅទុំសក្តិសមនូវរូបា នៅវត្តតីម៉ាគ្រូពីគ្រោះ
ប្រែជាចៅឯកប្លែកទាំងអស់ នៅទីវត្តនោះឈ្មោះតែបង ។
៨២-ឥឡូវនេះហើយទើបមកយល់ ឱប្អូននិមលវត្នស្នេហ៍ស្នង
កាលថ្ងៃទេស្នាឱ្យស្ដាប់ម្ដង ចិត្របងចងចាំកាលនោះណា ។
៨៣-ហើយលាលោកគ្រូប្រោសឱ្យសិក្ខ នៅវេលាព្រឹកចាកសិក្ខា
ហើយថ្វាយបង្គំចរយាត្រា វិលមកគ្រឹះហាឱ្យទាន់ចិត្រ ។
៨៤-ឥឡូវចូរប្អូនមាសទងរង រៀបរុងយកបងរួមស្នេហ៍ស្និទ្ធ
ជាគូកំពុងរង្សរួមរឹត សូមទាវអាណិតអាសូរបង ។
៨៥-មួយសោតខ្លួនបងគ្មានពំនឹង ពំនាក់ទីពឹងជាគូគ្រង

ចូរប្អូនមិត្រមាសថ្លៃទងរង
រៀបរុងទុក្ខបងឱ្យរសាយ ។
៨៦-ឯទាវឆ្លាយឆ្លើយតបទៅថា
ធ្វើហាក់មាយាដូចនឿយណាយ
ធ្វើជាមិនស្គាល់មិនមានស្ដាយ
តោះតើយនិយាយសាកសួរទៅ ។
៨៧-ថាខ្ញុំមិនបានស្គាល់ជាក់លក្ខណ៍
ពីឈ្មោះនៃអ្នកប្រុសឆោមឆ្នៅ
ពីកាលថ្ងៃនោះខ្ញុំចេញទៅ
ស្ដាប់ទេស្នានៅផ្ទះលោកតា ។
៨៨-ពុំបានឃើញអ្នកណាស្រដី
រសរុងសំដីសងវាចា
ឃើញតែអ្នកនេនឯកថ្លៃថ្លា
លោកមកទេស្នាថ្ងៃនោះឯង ។
៨៩-ចូរអ្នកដោះចាកចេញទៅក្រៅ
កុំអ្នកសៅដៅលកលលេង
ថៃចង់ខ្លួនខ្ញុំនេះជាល្បែង
ខ្ញុំមិនម្នាក់ឯងមានមាតា ។
៩០-ថាបើអ្នកមកនឹងចង់បាន
គួរតែរិលថ្កានរកមេបា
ឱ្យដើរដោយផ្លូវត្រូវមាត្រា
ខ្ញុំឥតបើថាណាអ្នកថ្លៃ ។
៩១-អ្នកដើរចូលមកយកខ្លួនឯង
អ្នកលួចលបលៃដូច្នេះនៃ
ហាក់ដូចខ្លួនប្រុងទុកសំច័យ
គ្រាន់តែប្រុសថ្លៃដើរមកលេង ។
៩២-អ្នកឯកឆ្លាស់ឆ្លើយតតបទៅ
ថាហៃប្អូនពៅនាងចេះថែង
ដោះសារខ្លួននោះស្អាតឱ្យស្អាតផេង
ម្ល៉េះហើយបងឯងយកឱ្យបាន ។
៩៣-នាងទាវស្ដាប់ជាក់ពាក្យអ្នកឯក
អាណិតពន់ពេកចង់រួមស្ថាន
ប្រាប់ថាបើអ្នកបើកទ្វារបាន
ខ្ញុំហ៊ានទទួលយកជាប្ដី ។
៩៤-ថាបើអ្នកបើកទ្វារពុំបាន
ជាក់ជាពុំមែនគូបេតី
ចូរអ្នកត្រឡប់ទៅវិញខ្មី
ខ្ញុំនឹងយកថ្មីឱ្យងាយៗ ។
៩៥-កាល្មោះអ្នកឯកស្ដាប់ជាងជាក់
ឃើញចិត្រទាវស្ម័គ្រចង់រួមកាយ
ត្រេកអរសាទរធូររីករាយ
សែកហៅមេព្រាយបើកទ្វារបាន ។
៩៦-នាងទាវឃើញឯកបើកទ្វារបាន
ប្រះទៅលើខ្នើយកើយសម្រាន្ត
យកភួយដណ្ដប់គ្របអស់ប្រាណ
ធ្វេសទេវិញ្ញាណភ្លេចស្មារតី ។
៩៧-អ្នកឯកផ្ដេកផ្ដិតចូលទៅទៀប
ដាក់ដៃទៅស្ទាបអង្អែលខ្មី
សរសើរដំណើរប្អូនពីសី
នាងល្អពេកក្រៃរកផ្ទឹមគ្មាន ។
៩៨-នាងទាវប្រែប្រាណធ្វើជាភ្ញាក់
ដឹងស្មារតីជាក់ធ្វើជាអៀន

ក្រោកឡើងសញ្ចប់ជប់ស្រមៀន　　ផ្ទប់កៀនរាំងននឯកឱបដាប់ ។
៩៩-អ្នកឯកញញឹមថើបភក្ត្រា　　លោមថាហៃប្អូនមាសចំណាប់
បើប្អូនមិត្រមាសមិនរងរ៉ាប់　　បងនិងត្រឡប់វិលទៅវិញ ។
១០០-នាងឮអ្នកឯកលាទៅវិញ　　ក្នុងចិត្រម្ដូម៉ៅស្ដីពុំចេញ
ពុំចង់ឱ្យឯកបែកចេញទៅវិញ　　ទ្វារចេញមកចាប់ផាហ៊ុមទុក ។
១០១-អ្នកឯកយល់នាងព្រមស្រាកស្រួល　　ឯកឱបផ្ដេកផ្ដួលថើបញីញក
រួមរក្សមនោរម្យសមសាន្តសុខ　　ស្បើយទុក្ខស្បើយថប់ក្នុងចិន្តា ។
១០២-អស្ចារ្យព្រះពាយផាត់ពពក　　នាគរាជលូនមកជ្រកគុហា
ទឹកជោរពោរពាសរងរុក្ខា　　ត្រែងត្រាវលាយវិលទៅ ។
១០៣-រលកបក់បោកខ្ទប់មាត់ច្រាំង　　ពពុះសោតបាំងមាត់ពាមក្រៅ
កម្លាំងនាគលូនជូនទឹកទៅ　　ខ្ទប់នឹងកោះហៅមល្លិកា ។
១០៤-ទាំងពីរភិរម្យសុខសប្បាយ　　ស្គាល់រសជាតិកាយត្រីអោមា
ផ្ដេកផ្ដិតជួយជិតចូលនិទ្រា　　ទៀបព្រឹកឯកលាទៅទាំងទុក្ខ ។
១០៥-ឯកទ្វារតែងទៅមករកគ្នា　　លុះត្រីមាសាបានជាសុខ
ដែលកើតហេតុកើតកលិយុគ　　ដើរច្រៀងសព្វស្រុកសព្វភូមិស្ថាន ។
១០៦-ឈប់ស្លេះនៅនេះនឹងពណ៌នា　　សម្ដេចរាមាមហាក្សត្រក្សាន្ត
ស្ដេចគង់ស្រះកែរសម្បូរបាន　　ឮល្បីអំណាចគ្រប់នគរ ។
១០៧-ស្ដេចគង់ប្រសើរលើប្រាសាទ　　សម្ដេចនរនាថសុខសាទរ
ទេពីស្នំស្និទ្ធគាល់រីករររ　　នាម៉ឺនកុះករគាល់ត្រៀបត្រា ។
១០៨-ស្ដេចមានតម្រាស់ត្រាស់ទៅខ្ទី　　នៃរើយតម្រួតចូរអស់គ្នា
ឯងទៅប្រាប់អក្ខរៈចិន្តា　　ឱ្យតែងឱង្ការចេញទៅប្រាប់ ។
១០៩-ឧកញ៉ាអរជូនជាស្ដេចត្រាញ់　　ឥឡូវថាអញអ្នកចង់ស្ដាប់
ចម្រៀងដែលច្រៀងយ៉ាងចំណាប់　　រើយឱ្យឆាប់ៗនាំមកថ្វាយ ។
១១០-តម្រួតក្រាបលារាចេញទៅខ្ទី　　ទៅដល់អាល័ក្សជាតួនាយ
ថ្លែងតម្រាស់ក្សត្រពណ្ណរាយ　　អក្ខរៈខ្វល់ខ្វាយតែងឱង្ការ ។
១១១-ស្រេចហើយប្រើទូតឱ្យចេញទៅ　　ស្រូតរូតដល់ខែត្រត្បូងឃ្មុំណា

អញ្ជើញរាជសព្ទប្រញាប់ការ  ឱកញ៉ាអរជូនថ្វាយបង្គំ ។
១១២- ហើយទើបលាកលាព្រះឱង្ការ  ថ្លែងដឹងរាចាការសុខដុម
ទើបប្រើភ្នាក់ងារមួយជាធំ  នាំរាជបំរើដើររើសរក ។
១១៣- បានដល់ភូមិមួយឈ្មោះជើងខាល  នៅស្រុកកណ្តាលឈប់សំកក
ដើរសួរអ្នកស្រុកគិតលៃលក  សួររកអ្នកច្រៀងនៅស្រុកអាយ ។
១១៤- មិនមានឃើញអ្នកឯណាមួយ  រូបឆោមត្រទ្រួលស្រស់ឆើតឆាយ
យល់តែអ្នកឯកថ្លែងទ្រង់ទ្រាយ  នៅដែនដីអាយរកផ្ទឹមគ្នាន ។
១១៥- ស្តាប់នូវសំដីក៏ពីរោះ  មុខស្រិលមាត់ស្រស់ស្ងួនសមប្រាណ
ច្រៀងសោតសម្លេងនោះក៏បាន  រោហារមិនមានអ្នកណាស្មើ ។
១១៦- អាជ្ញហៅឯកបានមកហើយ  ប្រាប់ថាឯកើយក្សត្រប្រសើរ
មានព្រះឱង្ការឱ្យយើងដើរ  យកឯកឯងតើគិតធ្វើម្តេច ។
១១៧- ឯកលើកដៃឡើងក្រាបសំពះ  ថាខ្ញុំបាទម្ចាស់នេះគ្មានគេច
មានតែលោកទៅយកចៅពេជ្រ  គូខ្ញុំនេះដាច់ខាងផ្លុំបី ។
១១៨- អាជ្ញាឮហើយប្រើគ្នីគ្នា  ឱ្យរត់ម្នីម្នាទៅឆាប់ខ្មី
ហៅបានចៅពេជ្រគេចរិលរៃ  ចៅឯកស្រដីប្រាប់ពេជ្រថា ។
១១៩- ប្អូនអើយមានព្រះបន្ទូលមក  ឱ្យយកពេជ្រឯងនិងអញណា
ចូលទៅឧដុង្គថ្វាយក្សត្រា  តាំងបងឱ្យជាចំរៀងថ្វាយ ។
១២០- លុះបានជួបចូលរាត្រីស្ងាត់  ចៅឯកដើរកាត់ទៅពីអាយ
ដល់ឋាននាងទារះឆើតឆោមឆាយ  ផ្តាំពាក្យប្រាជ្ញប្រាយឱ្យដឹងជាក់ ។
១២១- ថាហៃមិត្រមាសថ្លៃបងអើយ  បងនឹងឃ្លាតហើយណាររលក្ខណ៍
ឃ្លាតពីដំណែលតែងរួមរ័ក្ស  ឆ្ងាយពីដំណាក់ដំណេកស្រី ។
១២២- ឃ្លាតពីពូកព្រំថៀមចំខ្នើយ  កន្ទេលស្បែកហើយខ្នើយឱបថ្មី
ដ្បិទមានអាជ្ញាព្រះជៀស្តជ័យ  ចូលមកស្រដីយកបងទៅ ។
១២៣- ទុកដាក់ឱ្យជាចម្រៀងថ្វាយ  ក្សត្រាពណ្ណរាយស្តេចគង់នៅ
បន្ទាយស្រះកែវណាប្អូនស្រីពៅ  ឃើញជាបងទៅឃ្លាតប្អូនភ្ងា ។
១២៤- នាងទារះបានឮពាក្យអ្នកឯក  ក្នុងទ្រូងស្ទើរបែកញរ័រអង្គា

ដ្បិតថាមានអស់ទាំងអាជ្ញា នានាំឯកជាស្វាមីទៅ ។

១២៥-ហើយសោកថាឱអ្នកប្រុសថ្លៃ ធ្លាប់វែងមេត្រីមូលលំនៅ
ឥឡូវនេះហើយឃ្លាឃ្លាតទៅ ចោលប្អូនឱ្យនៅតែម្នាក់ឯង ។

១២៦-ចៅឯកលួងលោមថ្លើមសង្សារ ថាហៃប្អូនភ្ងាកុំចំបែង
បើជាក់ជាគូ(មក)ពីព្រេង គង់តែប្អូនឯងជួបនឹងបង ។

១២៧-ចៅឯកលាកលាចាកចេញទៅ ទាំងទុក្ខក្តួលក្តៅភក្ត្រសៅហ្មង
ដើរដល់ផ្ទះម្តាយឯកហើយហោង ប្រាប់ដោយទំនងពីបំរើ ។

១២៨-ឯម្តាយអាពុកពុំហ៊ានឃាត់ កូនស្ងួនកំសត់រៀបដំណើរ
តាមចិត្រជំពោះស្មោះស្ម័គ្រស្មើ ឯកពេជ្រចុះដើរចាកចេញទៅ ។

១២៩-ចតទូកនិត្យនៅនាមាត់ពាម ទឹកហូរអន្លាមសាត់ចកស្មៅ
អ្នកឯកអ្នកពេជ្រចរចុះទៅ នាវាធំនៅទាំងពីរនាក់ ។

១៣០-ចៅពេជ្រទាញប៉ីយកមកផ្លុំ ឯឯកច្រៀងផ្សំពុំមានអាក់
រាប់ស្រុករាប់កោះចន្លោះថ្នាក់ ជ្រុងជ្រោយដំណាក់អស់មច្ឆា ។

១៣១-ចាត់ចែងលើកលេងពាក្យប្រាំពីរ ឈប់ទុកបង្វិលពាក្យបួនណា
ឥឡូវយើងនឹងចែងចរចា អ្នកឯកច្រៀងស្នេហាច្រៀងរាប់ស្រុក ។

## ពាក្យបួន

១៣២-កាលដល់មាត់ពាម ទឹកហូរអន្លាម អ្នកឯកជាទុក្ខ
នឹកដល់សង្សារ ស្នេហាជាឱក ពុំបានស្បើយទុក្ខ
រួតរឹងក្តួលក្តៅ ។

១៣៣-ស្រែកច្រៀងទៅថា ហៃទាវស្នេហា ដល់មាត់ពាមក្រៅ
ប្រសិនបានស្ងួន ខ្លឹមខ្លួនស្នេហា មូលមួយមកនៅ
នឹងបងតិចរ៉ា ។

១៣៤-តាំងពីរួមស្ថាន ជួបចូលសម្រាន្ត បានធូរឱរា
ឥឡូវម្តេចឡើយ ប្រាសពីប្អូនភ្ងា ឱ្យបងកំព្រា

ឃ្លាឃ្លាតប្អូនឯង ។

១៣៥- ឱស្រណោះណា ដល់កោះបីជា ធារធំចិញ្ចែង
មួយកោះសំរោង ដងក្តោងជ្រូកឯង ដល់កោះល្ពងតែង
តែងជាប់នឹងគ្នា ។

១៣៦- មានស្រុកមួយនោះ ហៅកំពង់ចន្លោះ ចុះបឹងព្រួលណា
មួយហៅជីរោ ពោះពាសថ្មដា មានឈូងមួយណា
ហៅកៀនតាផិង ។

១៣៧- មានជ្រយតាព្រហ្ម គេហៅទន្លេអុំ អ្នកផងតែងដឹង
ខ្លះហៅទន្លេបិទ ថ្មជិតសូន្យឈឹង ជ្រយកៀនតាផិង
ជុំនឹងស្រុកតិច ។

១៣៨- ដល់ព្រែកដូនសៅ[227] ទើបនឹងវិលទៅ វៀបកោះកៀនកើស
កោះកំពង់គ្រុប[228] ភូមិដីដុះខ្សាច់ កំពង់ចាមស្រេច
លេចដល់កោះគល់ ។

១៣៩- កោះប្រលូងមែន បើមើលមែនទែន ធារធំយង់យល់
មានកោះសូទិន សូបិនទសពល ទើបនឹងវៀបដល់
កោះរកាប្រាក់ ។

១៤០- ឯកោះរកា ចិនច្រើនដូចផ្សារ ដើរលេងរាក់ទាក់
ឆ្លងទៅឆ្លងមក លក់ដូរឥតអាក់ កោះគល់កោះប្រាក់
សប្បាយដូចគ្នា ។

១៤១- ប្រលឹងបងអើយ ជ្រួយបាំងអស់ហើយ ពុំយល់ប្អូនភ្ងា
ប្រសិនបានខ្លួន ខ្ទឹមខ្លួនពុំងា មើលអស់មច្ឆា
ហែបហែលដោយកោះ ។

១៤២- មានពាមមួយណា លោកតែងហៅថា ពាមផ្កាម្រេចនោះ

[227]Ms P. camb. 32: ដូនម៉ៅ

[228]Ms. P. camb. 32: កុំពង់គ្រុម

ទឹកហូរចេញចូល  មិត្រមូលឡើងចុះ  ត្រឹមក្បាលកោះនោះ
ពុំដែលហៅដាច់ ។

១៤៣-វីកោះសូទិន  ច្រើនខ្មែរច្រើនចិន  ពលព្រឹន្ទរហិច
ស្រុកនោះសប្បាយ  ពណ្ណរាយស្មើស្ដេច  ឈ្មួញឈ្មាញដើរត្រាច់
លេចទូកតូចធំ ។

១៤៤-ឯត្រើយឯត្បូង  ភូមិព្រៃរំលោង  ខ្ពស់ស្ដែងសុខដុម
ជាទីស្ងប់ស្ងាត់  អស់សត្វផងឃុំ  បីដូចព្រៃធំ
ជុំសត្វបក្សី ។

១៤៥-ក្ងូក្អែក  ក្ងានបោលតោក  រកភត្តចំណី
កុកក្រកកុកគ្រោង  ឈោងចាប់ផ្ដុំដី  ហើររកចំណី
ខ្ញីញីឈ្មោលរា ។

១៤៦-តែអង្គអញឯង  ប្រាសឆ្ងាយអង្វែង  ពុំយល់ប្អូនភ្ងា
ម្ល៉េះសមប្អូនស្ងួន  ព្រួយតែងទុក្ខា  សង្រេងខ្លោចផ្សា
ទល់ទុក្ខធ្ងន់ក្រៃ ។

១៤៧-បើទាវមកវ៉ា  នឹងមើលមច្ឆា  កៀងគូទីទៃ
ឥឡូវបានដល់  ចុងកោះមួយនៃ  អាផ្ញាសោតក្រៃ
វៃរាតចូលចត ។

១៤៨-ហៅស្រុកជ្រួយក្ដាត់  ចូលសួរសព្វញាតិ  ព្រៀងលានដោយបទ
ឯខ្លួនបងឯង  ជាអ្នកកំសត់  គ្មានញាតិណាជិត
ព្រាត់ពីសង្សារ ។

១៤៩-លុះទូកចេញទៅ  ដល់ស្រុកបីហៅ  ភូមិមហាសៀកណា
មួយឈ្មោះភូមិជ្រៃ  ព្រៃឯកើតណា  ឈប់ដេកនៅនា
ស្រុកទាំងបីកោះ ។

១៥០-អាផ្ញាប្រើគ្នា  រកសូមមាន់ទា  ឱសភ្លើងចន្លុះ
ដណ្ដាំបាយស្ល  អាំងឧបន្ទោះ  ប្រហុកបង់ស្រុស
អន្លក់ស៊ីបាយ ។

១៥១-លុះព្រឹកព្រាងស្រេច ថ្ងៃរះបន្តិច ចេញទូកប្រញាយ
កាត់ទៅក្បាលកោះ ចន្លោះមិនឆ្ងាយ មើលទៅត្រើយនាយ
ឃើញពាមជីកង ។

១៥២-មានស្រុកមួយទៀត ជិតគ្នាមកបៀត ឈ្មោះខ្សាច់ស្អិតផង
ដើរទៅដើរមក រកពាមជីកង ទើបចេញកាត់ឆ្លង
ទៅកោះកំបោរ ។

១៥៣-បានដល់អូរខ្សាច់ ថែរជ្រួយមួយលេច ដាច់ដល់ចុងអូរ
ភូមិឫស្សីស្រុក ឈ្មួញលក់ហៃហូរ ស្រុកនោះសម្បូរ
អាហារភោជន ។

១៥៤-ឯត្រើយឯជើង ស្រុកនោះធំថ្កើង ឮមកពីមុន
ហៅអង្គរបាន ប្រសើរពេកពន់ ក្រឡេកគយគន់
ទៅឃើញថ្លុកជ្រៅ ។

១៥៥-ភូមិកោះតាង៉ោរ ឈ្មួញលក់កំបោរ ទាំងស្រីទាំងប្រុស
ឆោឡោរញៀរ ស្រួលស្រុះលក់ដូរ កំបោរយកទៅ
ដោយផ្ទះអាត្មា ។

១៥៦-ឯអង្គឯកឯង ឃ្លាតទៅចំបែង ខ្វែងស្រុកពីគ្នា
ព្រាត់ទាំងស្វាម្ល បារីផងណា នេះគឺវេរា
កម្មពីព្រេងនាយ ។

១៥៧-ឱ្យថ្លៃបងអើយ ដល់ស្រុកទៀតហើយ បងអើយមិនឆ្ងាយ
ឈ្មោះត្នោតល្វាទ្រេត ទៀបនិងស្រុកស្វាយ បន្ទាបមកអាយ
ស្វាយគាតផ្ទះវាល ។

១៥៨-កាត់ជ្រោយក្រចៅ ក្រឡេកមើលទៅ ចុងបឹងផ្ទះកណ្តាល
ស្រុកនោះសប្បាយ ឆ្ងាយដាច់ស្រយាល មានព្រៃកកណ្តាល
វាលឈ្មោះមាត់ពាម ។

១៥៩-ស្រុកមួយក្រោមទៀត បន្ទាបប្រហៀត ឈ្មោះព្រៃកពោរាម
មួយឈ្មោះរកាទ្វា វេរាដើរតាម ព្រៃកហូរអន្លាម

ពាមកំពង់សំរែ ។

១៦០-ស្រុកនោះទុរគម ដើមឈើសុខដុម ហៅភូមិទូរី
ខ្មែរចិនដូរលក់ ទំនិញប្រក្រតី ចេញចូលឥតបី
ស្ដីដូចបន្ទាយ ។

១៦១-ឯខាងឯជើង បើនឹងរៀបឡើង ឱ្យអស់ពីអាយ
ភូមិរកាអារ មានកោះមិនឆ្ងាយ ជិតច្រាំងពីនាយ
ឆ្ងាយពីត្រើយត្បូង ។

១៦២-មានភូមិត្រឡោក បើនឹងរៀបបោក ចាប់មកយិតយោង
ភូមិកងតាណឹង មានបឹងរំលោង ព្រៃធំហឹតហោង
ជ្រលងព្រៃផង ។

១៦៣-រីត្រើយខាងកើត ចាស់លោកបង្កើត ឈ្មោះបាសានហោង
ចុះទៅក្រោមទៀត បៀតគ្នានោះផង ស្រុកមណ្ឌបចង
ចាំទុករៀងមក ។

១៦៤-ទៅដល់ភូមិល្វា ទេរទៀបនិងគ្នា ភូមិជ័យជុំជ្រក
ដល់ភូមិតាឯក បែរភាគេចមក ភូមិត្រាងចាប់យក
មកកោះចូរ៉ាម ។

១៦៥-រីត្រើយខាងលិច ភូមិនោះក៏ដាច់ កៀចគេចសឹងព្យាម
តាំងពីភូមិស្ដៅ ហៅព្រែកពោរាម បណ្ដោយមាត់ពាម
ភ្លាមដល់រកាកោង ។

១៦៦-កោះពីរពន្លឹក ហ្វូងសត្វរអឹក គគឹកឆាបឈោង
ចាប់អស់មច្ឆា រអាដោយហ្វូង ខ្លះធំរយោង
ទាំងហ្វូងហើរទៅ ។

១៦៧-ក្អែកទឹកទាទឹក ចុះស៊ីសន្ធឹក ដោយខ្យាច់ឈប់នៅ
ដោយពួកដោយកន បនភាហើរទៅ សំកាំងទំនៅ
ដោយមែករុក្ខា ។

១៦៨-សត្វស្មោញតបលាយ ហិចហើរប្រញាយ ចុះទៀបក្រសារ

ទុងទាំងប្រវឹក រអឹកភោក្កា ចាប់អស់មច្ឆា
ជាភត្តចំណី ។

១៦៩-រំពេក្ងាន ចាប់ត្រីតាមដាន ឆ្វៀលខ្សាច់ដាច់ដី
ដោយដងជ្រលង ទំនងផុសថ្មី ឱសត្វបក្សី
ខ្វីឃ្មាតរកស៊ី ។

១៧០-ខ្លែងអកអាអាត ហិចហើរសង្វាត ឈោងឆាបចាប់ត្រី
សកក្រឱ៍ នូវមាន់ទឹកទី ទុយទំប្រុបព្រៃ
ទាំងគូញីឈ្មោល ។

១៧១-ឯអស់មច្ឆា ហក់ហែលរេរា ដាលដេញកញ្ជ្រោល
ឆ្លាំងឆ្លាមហែលដល់ យល់ផ្សោតកំរោល រលកខ្មោលៗ
ពុំដែលហៅភ្លឹក ។

១៧២-ក្រពើមករ បរបែលហែលមក៍ រកដេញពន្លឹក
ឯអស់មច្ឆា រអាក្នុងទឹក ឥតឯមានភ្លឹក
ចឹកចាប់ភោក្កា ។

១៧៣-មានត្រីច្រកែង កែសកែប្រាក់ប្រា ដងខ្ទែងខ្ទប់ចាប់ចង្វា
ប្លមូប្លម៉ា ប្លមូគជ្រាត្រឱន[229] កន្ត្រប់ត្រីខ្លា
ក្រមាល់ប្រាវាជ ។

១៧៤-កញ្ច្រូកកញ្ចុះ កំបុតច្រមុះ កញ្ចុះក្តោងស្វាច
ខ្ទឹងកញ្ចាក់ស្លា ប្រាក់ប្រាព្រួលចាប់ ខ្វាត់ទឹកសស្វាច
រីរាត់កន្ទុយ ។

១៧៥-កន្ត្រប់កន្ត្រង បង្ការបង្កង ដងខ្ទែងពោព្រុយ
ត្រីក្អីត្រីក្អុក កំភ្លុកទីទុយ កំភ្លាញដុសព្រុយ
ក្រមាល់គល់រាំង ។

១៧៦-អណ្តើកត្រសែ ហែបហែលរិលរៃ ពួនប្រុបមាត់ច្រាំង
កន្ធាយល្មេច គេចបៀតបែរបាំង ខណ្ឌបៀតមាត់ច្រាំង

---

229 Le 3ème vers et le 5ème de la strophe 173 ont chacun deux syllabes de trop.

ទាំងគូឈ្មោលញី ។

១៧៧-កម្មអ្វីតែអញ ប្រាសប្អូនសម្លាញ់ ពេញទុក្ខសែនទ្វី
ប្រសិនបើស្ងួន រួមរក្សទាំងពីរ សប្បាយឥន្ទ្រីយ៍
គ្មានទុក្ខទោសា ។

១៧៨-ដល់ជ្រោយមេត្រី បងផ្អកដល់ស្រី មិត្តមាសស្ងួនភ្ងារ
មើលត្រើយឯកើត អើតឃើញភូមិស្លា បើប្អូនមករ៉ា
បានដល់យល់ស្រុកផង ។

១៧៩-ភូមិត្រាងព្រែកប្រសព្វ ចេញស្រូតទាំងយប់ ពុំឈប់កាត់ឆ្លង
ដល់ស្វាយតាគង់ ឆ្លងពុកឫស្សី ----
---- ។ [230]

១៨០-កាត់ទៅកោះខ្សាច់ កណ្ដាលបន្តិច ធ្មេចដេកទីទៃ
ឈរឈប់សម្រាន្ត បានស្បើយហទ័យ ទូកសោតលឿនក្រៃ
ទៅដល់ខ្នុរយក ។

១៨១-លុះព្រឹកឡើងហើយ ពុំដឹងហត់នឿយ ដល់ព្រែកលាភឈប់
ខ្លះសុំមាន់ទា ម្លូរស្លាចុះចប់ ខំរូតពុំឈប់
មកដល់កៀនឃ្លាំង ។

១៨២-អាដ្ឋាម្ទីម្នា អ្នកខ្លះបោចទា ខ្លះរារកឆ្នាំង
ដណ្ដាំបាយស្ល ខ្លះខខ្លះអាំង ខ្លះបេះស្លឹកថ្នឹង
ផ្សំប្រហុកឆៅ ។

១៨៣-ឮមាន់រងាវ ឯកនឹកដល់ទាវ ទៀងទួញសុបសៅ
ថាឱប្អូនស្ងួន ខ្លឹមខ្លួនល្ហេញល្ហៅ បានជាទុក្ខក្ដៅ
ដ្បិទពៅឃ្លាតឆ្ងាយ ។

១៨៤-ប្រលឹងបងអើយ ផុតកៀនឃ្លាំងហើយ ប៉ាំងកោះស្នាអាយ
ជិតជ្រោយចង្វា បងឃ្លាតប្អូនឆ្ងាយ ទើបឃើញបន្ទាយ
ឆ្ងាយត្រើយខាងកើត ។

[230]Cette strophe manque deux vers.

១៨៥-មើលទៅស្វាយជ្រំ ឃើញហើយចង់យំ បងខំតែអើត
ឃើញភូមិល្វាឯម អរិយក្សត្រឯកើត ប្អូនអើយបងអើត
ងើយមើលពុំយល់ ។
១៨៦-ទន្លេប្អូនមុខ ដល់ហើយកើតទុក្ខ ជាឱកអំពល់
បើសិនទាវមក បងឥតកង្វល់ ប្អូនអើយបងដល់
យល់តែម្នាក់ឯង ។
១៨៧-ទន្លេប្អូនមុខ ដល់ហើយកើតទុក្ខ ឈាមចុកជាបែរ
ប្រសព្វមកស្តែង នឹងគន់ទៅទឹក ទឹកហូរល្វែងៗ [231]
រលកបែកផ្កាត្រែង តែងផុំមច្ឆា ។
១៨៨-ប្រលឹងបងអើយ ដល់ភ្នំពេញហើយ បងឡើងលេងផ្សារ
ប្រសិនបានស្ងួន ខ្លឹមខ្លួនពុំងា នាងមកផងគ្នា
នឹងងាយដើរលេង ។
១៨៩-ពាក្យប្អូនឈប់ស្លេះ នឹងប្រែត្រឡប់ ពាក្យប្រាំពីរឯង
អ្នកឯកអ្នកពេជ្រ គិតស្រេចដើរលេង សប្បាយដោយល្បែង
កុំឱ្យថប់ពេក ។

(បទពាក្យ៧)

១៩០- ប្រាំពីរពាក្យអ្នកពេជ្រអង្វរ អស់អាជ្ញាសូមនាយមេត្តា
ចៅឯកព្រោះឃ្លាតសង្សារមកឆ្ងាយពេក ឃើញមុខចម្លែកជាងសព្វដង ។
១៩១-សូមនាយអាណិតឈប់សិនវ៉ា បើកឱ្យលេងផ្សារមើលទ្រព្យ
ឱ្យគាត់សប្បាយចិត្របានម្តង ទំនងនឹងភ្លេចគិតភរិយា ។
១៩២-ឯអស់អាជ្ញាក៏ស្រាកស្រួល ព្រាកព្រមស្រាកស្រួលពាក្យពេចន៍ថា
ថប់ក្រែងវាឈឺគ្រុនរងា នឹងខាតខូចការខុសដល់ប្រាណ ។
១៩៣-លុះថ្ងៃរសៀលទន់ត្រជាក់ ឯកពេជ្រពីរនាក់ឡើងទៅថ្កាន
ដើរលេងមើលអស់ចិនដាក់វាន មិនមានឱ្យខ្វះរបស់អ្វី ។

[231] Dans cette strophe, il y a un vers de quatre syllabes de trop.